ក្រសួងសង្គមកិច្ចការងារ
និងអតីតយុទ្ធជន
លេខ ២២ ស.ក.អ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ប្រកាស
### ស្តីពី
### នីតិវិធី នៃការដោះស្រាយវិវាទបុគ្គល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជណាចក្រ កម្ពុជា
-បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣
-បានឃើញច្បាប់ការងារ

### <u>សម្រេច</u>

**<u>ប្រការ១</u>** ក្នុងការជម្រះវិវាទការងារ មុននឹងប្តឹងទៅតុលាការគ្រប់រឿងវិវាទបុគ្គលត្រូវតែភាគីណាមួយប្តឹងទៅអធិការការងារឬអភិបាលការងារ ដើម្បីធ្វើការផ្សះផ្សាជាមុនសិន ។

នាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន ស្ថិតនៅអគារលេខ ២៨ ផ្លូវ សម្តេចព្រះធម្មលិខិតអ៊ុក សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ មានសមត្ថកិច្ចទទួលខុសត្រូវផ្សះផ្សាវិវាទការងារនៅ រាជធានីភ្នំពេញ ។

អធិការដ្ឋានសង្គមកិច្ចការងារ និងអតីតយុទ្ធជន ខេត្ត ក្រុង ដទៃទៀតមានសមត្ថកិច្ច ទទួលខុសត្រូវផ្សះផ្សាវិវាទការងារនៅខេត្ត ក្រុងរៀងៗខ្លួន ។

**<u>ប្រការ២</u>** ក្រោយពីបានទទួលបណ្តឹងពីភាគីណាមួយ អធិការការងារ ឬ អភិបាលការងារ ត្រូវធ្វើលិខិតអញ្ជើញទៅភាគីទាំងអស់មកផ្តល់នូវព័ត៌មាន និងឯកសារជាភស្តុតាងនានា ដែលខ្លួនចង់បានដើម្បីផ្សះផ្សាវិវាទឲ្យបានសមស្រប ។

ការសាកសួរព័ត៌មានបន្ថែមនេះត្រូវធ្វើឡើងមួយភាគីម្តងដាច់ដោយឡែកពីគ្នា ។ គ្រប់ពេលសាកសួរព័ត៌មានបន្ថែមត្រូវធ្វើកំណត់ហេតុទុកជាឯកសារដោយមានចុះហត្ថលេខាអធិការ ឬអភិបាលការងារ និងភាគីដែលផ្តល់ព័ត៌មាននោះផង ។

**<u>ប្រការ៣</u>** បើភាគីដើមចោទ ឬ តំណាងនៃជននេះមិនព្រមអញ្ជើញទៅផ្តល់ព័ត៌មានបន្ថែមជូនអធិការ ឬ អភិបាលការងារតាមកាលកំណត់ ឬក្នុងរយៈពេល៣ថ្ងៃ យ៉ាងយូរបន្ទាប់ពីថ្ងៃផុតកំណត់គិតតែថ្ងៃធ្វើការ ដោយគ្មានមូលហេតុសមស្របទេនោះ ពាក្យបណ្តឹងនោះត្រូវទុកជាមោឃៈ ។

បើភាគីចុងចោទ ឬតំណាងនៃជននេះមិនព្រមចូលបង្ហាញខ្លួនក្នុងចិរវេលា ឬ ដោយមូលហេតុដូចមានកំណត់ក្នុងកថាខ័ណ្ឌទី១ នៃប្រការ៣ នេះរឿងវិវាទត្រូវចាត់ទុកថាមិនសះជា ហើយត្រូវចាត់ទុកថាភាគីចុងចោទមានកំហុសដូចការចោទប្រកាន់របស់ភាគីដើមចោទទាំងស្រុង ។

**<u>ប្រការ៤</u>** បន្ទាប់ពីបានទទួលព័ត៌មានសព្វគ្រប់អស់ហើយ អធិការ ឬអភិបាលការងារត្រូវធ្វើលិខិតអញ្ជើញម្តងទៀត ឲ្យភាគីទាំងសងខាងចូលរួមប្រជុំជាមួយគ្នាដើម្បីធ្វើការផ្សះផ្សា ។ភាគីវិវាទអាចឲ្យគេជួយអមណា ឬឲ្យគេតំណាងខ្លួនបាន ។

បើភាគីដើមចោទ ឬតំណាងជននេះមិនចូលរួមប្រជុំតាមការកំណត់ ហើយគ្មានបញ្ជាក់មូលហេតុសមស្របទេ រឿងវិវាទត្រូវចាត់ទុកថាមិសះជា ហើយត្រូវចាត់ទុកថាភាគីចុងចោទមានកំហុសដូចការចោទប្រកាន់របស់ភាគីដើមចោទទាំងស្រុង ។

**ប្រការ៥** លិខិតអញ្ជើញដែលមានចែងក្នុងប្រការ២ និងប្រការ៤ ត្រូវធ្វើជូនភាគីតាមសំបុត្រអនុសិដ្ឋ ដែលមានហត្ថលេខាចុះបញ្ជាក់ថាបានទទួលហើយ ។

**ប្រការ៦** ជនទាំងឡាយនិងអាចជួយអម ឬធ្វើជាតំណាងរបស់ភាគីវិវាទបានលុះត្រាតែជននោះជាមនុស្សពេញវ័យដែលច្បាប់ទទួលស្គាល់ ហើយឲ្យសម្រេចកិច្ចការបានផង ។

**ប្រការ៧** ត្រូវធ្វើកំណត់ហេតុទៅរាល់ពេលប្រជុំផ្សះផ្សាដោយមានបញ្ជាក់ច្បាស់លាស់ពីការយល់ព្រម ឬមិនយល់ព្រមសះជានឹងគ្នា ។ កំណត់ហេតុនោះត្រូវចុះហត្ថលេខាដោយអធិការ ឬអភិបាលការងារព្រមទាំងហត្ថលេខារបស់ភាគីទាំងសងខាងនិងត្រូវចម្លងចែកភាគីផង ។

**ប្រការ៨** ក្នុងករណីសះជាគ្នា បើភាគីណាចង់យកកំណត់ហេតុនេះទៅអនុវត្តភាគីនោះត្រូវទៅប្តឹងចាងហ្វាងតុលាការការងារ ឬបើពុំទាន់មានតុលាការនេះទេត្រូវទៅប្តឹងប្រធានតុលាការខេត្ត ក្រុង សុំឲ្យចេញដីកាសម្រេចឲ្យចុះលើកំណត់ហេតុរបស់អធិការការងានូវរូបមន្តបង្គាប់ឲ្យប្រតិបត្តិកំណត់ហេតុនោះតែម្តង ។ការប្រតិបត្តិកំណត់ហេតុត្រូវប្រព្រឹត្តទៅហូរហែដូចជាសាលក្រមតុលាការការងារដែរ ។

ប្រធានតុលាការដែលមានសមត្ថកិច្ចនោះ គឺប្រធានតុលាការខេត្ត ក្រុង ដែលកំណត់ហេតុនៃការផ្សះផ្សាបានធ្វើនិងចុះហត្ថលេខា ។

**ប្រការ៩** ក្នុងករណីសះជា ដោយរាប់ទាំងការមិនសះជាដែលមានកំណត់ក្នុងប្រការ៣ និងប្រការ៤ ខាងលើអធិការ ឬអភិបាលការងារត្រូវជម្រាប់ទៅភាគីអំពីសិទ្ធិរបស់ភាគីដើមចោទដែលអាចធ្វើពាក្យប្តឹងជាបន្តទៅតុលាការមានសមត្ថកិច្ចទៅតាមបែបបទដែលមានកំណត់ក្នុងច្បាប់ ។ អធិការ ឬ អភិបាលការងារត្រូវផ្តល់ជូនទៅភាគីនូវកំណត់ហេតុនានាខាងលើដើម្បីបំពេញសំណុំរឿងនៃការប្តឹងបន្តនោះផង ។

**ប្រការ១០** ប្រការនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៤

**រដ្ឋមន្ត្រី**

**ស៊ុយ សែម**

ចម្លងជូន

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងយុត្តិធម៌
-ដើម្បីជ្រាប
-ក្រសួងព័ត៌មានដើម្បីផ្សព្វផ្សាយទូលំទូលាយ
-រាជកិច្ច
-កាលប្បវត្តិ
-ឯកសារ